# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

## សេចក្តីប្រកាសព័ត៌មាន
## អ្នកនាំពាក្យ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

- អ្នកនាំពាក្យក្រសួងការពារជាតិ សូមប្រកាសបដិសេធ ថ្កោលទោស ចំពោះពាក្យប្រមាថមើលងាយ មកលើតួនាទីរបស់កងយោធពលខេមរភូមិន្ទ ពីសំណាក់លោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិ និយាយកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ហើយត្រូវបានដកស្រង់សម្តី និងចុះផ្សាយតាមរយៈសារព័ត៌មាន Cambodia daily ច្បាប់ចេញផ្សាយ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ ដែលបានលើកឡើងថា " រាជរដ្ឋាភិបាលដែលបង្កើតឡើងដោយរដ្ឋសភាខុសច្បាប់នេះ គឺជារដ្ឋាភិបាលខុសច្បាប់ ហើយកងទ័ពដែលបំរើឲ្យរាជរដ្ឋាភិបាលខុសច្បាប់ ក៏ខុសច្បាប់ដែរ " ។
- ការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា នីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣ បានប្រព្រឹត្តិទៅដោយរលូន គ្មានអំពើហិង្សា មានលក្ខណៈសេរី យុត្តិធម៌ និងមាន តម្លាភាព ក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាពល្អ តាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ ការប្រកាសលទ្ធផលជាផ្លូវការបង្ហាញថា គណបក្សប្រជាជនកម្ពុជា ទទួលបាន ៦៨ អាសនៈ ក្នុង ចំណោមអាសនៈរដ្ឋសភា សរុប ១២៣។
- សម័យប្រជុំលើកដំបូងនៃរដ្ឋសភា នីតិកាលទី៥ ប្រារព្ធធ្វើឡើងថ្ងៃទី២៣ និង២៤ ខែកញ្ញា ឆ្នាំ ២០១៣ នៅវិមានរដ្ឋសភា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ។ កិច្ចប្រជុំនេះ បានប្រព្រឹត្តិទៅដោយរលូនតាមច្បាប់ ទោះបីមិនមានវត្តមានរបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ក៏ដោយ ។ ក្នុងពេលប្រជុំ ព្រះមហាក្សត្របានត្រាស់បង្គាប់ ចាត់តាំង **សម្តេចតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រេចអនុម័តសុពលភាពអាណត្តិរបស់សមាជិកនីមួយៗ អនុម័តផ្តល់សេចក្តីទុកចិត្ត ចំពោះសមាសភាពរបស់រាជរដ្ឋាភិបាល នីតិកាលទី ៥ ។

- ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ នៃរដ្ឋសភា គណបក្សប្រឆាំង ដែលមិនព្រមចូលក្នុងរដ្ឋសភា ហើយធ្វើការអូសទាញប្រជាពលរដ្ឋ កម្មករ ចូលរួមធ្វើបាតុកម្មយ៉ាងអាណាធិបតេយ្យ ដោយមិនគោរពច្បាប់ បន្តលើកឡើងដដែលៗ នូវការទាមទាររបស់ខ្លួនដែលគ្មានមូលដ្ឋានការពិត ផ្ទុយពីរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន រហូតដល់ចុងក្រោយនេះ ទាមទារឲ្យមានការបោះឆ្នោតឡើងវិញ និងឲ្យ **សម្តេចតេជោ ហ៊ុន សែន** ចុះចេញពីតំណែងទៀតផង។
- ស្ថិតក្នុងសភាពការណ៍ដែលសន្តិសុខ សណ្តាប់ធ្នាប់សង្គមជាតិ ត្រូវបំផ្លាញ ធ្វើឲ្យប៉ះពាល់ដល់ភាពសុខដុមរមនា ការរីកចំរើនរបស់ប្រទេសជាតិ កងយោធពលខេមរភូមិន្ទ ត្រូវការពារដាច់ខាតរដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាលស្របច្បាប់ ដែលបានជ្រើសតាំងដោយរដ្ឋសភាស្របច្បាប់។
- ជាថ្មីម្តងទៀត អ្នកនាំពាក្យក្រសួងការពារជាតិ ប្រកាសបដិសេធ និងថ្កោលទោស ដាច់ខាតការប្រមាថ មាក់ងាយមកលើកិត្តិយស និងសេចក្តីថ្លៃថ្នូរ របស់កងយោធពលខេមរភូមិន្ទ។
- ទន្ទឹមនឹងនេះដែរ សូមអំពាវនាវដល់នាយទាហាន ពលទាហាន នៃកងយោធពលខេមរភូមិន្ទ មេត្តាបន្តការអត់ធ្មត់ ចំពោះការប្រើពាក្យពេជន៍ប្រមាថមាក់ងាយ របស់លោក យឹម សុវណ្ណ មកលើកងយោធពលខេមរភូមិន្ទ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៤*